ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប

# កំណត់ហេតុ

## កិច្ចប្រជុំជំនាញពាក់ព័ន្ធ និងការរៀបចំគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី ស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែឧសភា ថ្ងៃទីដប់ប្រាំបី វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបើកកិច្ចប្រជុំពិភាក្សាជំនាញពាក់ព័ន្ធ លើការរៀបចំគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធមួយចំនួនដូចជា៖

| | | |
|---|---|---|
| ១. ឯ.ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ២. ឯ.ឧ | ប៉ែន ពេជ្រសាលី | អគ្គនាយក ក្រសួងយុត្តិធម៌ |
| ៣. ល.ជំទាវ | ឱ វណ្ណឌីន | អគ្គនាយកបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល |
| ៤. ឯ.ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៥. ឯ.ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៦ ល.ជំ ឧ.ឯក | ប៊ុណ្ណ សំខាន់ | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៧. ឯកឧត្តម | អ៊ូច ចាន់ណូរ៉ា | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ៨. លោកជំទាវ | រ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ៩. ឯ.ឧ ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| ១០. ល.ឧ.ទោ | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប គ.ជ.ប.ជ |
| ១១. ល.ឧ.ទោ | សំ វីរៈ | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ |
| ១០. ល.ឧ.ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន គ.ជ.ប.ជ |
| ១២. លោក | យឹម សំអុល | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម |
| ១៣. ល.វ.ឯក | ឆាន វុធ | ប្រធានការិយាល័យ នៃនាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ១៤. លោក | ណុប រដ្ឋា | ប្រធានការិយាល័យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ១៥. លោក | ចាប សៀកឆាយ | នាយករងវិទ្យាស្ថានជាតិ សុខភាពសាធារណៈ ក្រសួងសុខាភិបាល |

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញចូលរួមប្រជុំនាឱកាសនេះ។ លោកជំទាវ បានមានប្រសាសន៍ទាក់ទង សជណ លេខ២៥៣ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ និងលើកពីការរៀបចំគោលការណ៍ណែនាំ **ស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស** រឿងនេះគួរត្រូវបញ្ចប់នៅថ្ងៃនេះ ដើម្បីកុំឲ្យមានការអូសបន្លាយពេលវេលាយូរ ព្រោះខ្ញុំទទួលបានព័ត៌មានពីខាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ថា មានការនាំចេញទារកទៅក្រៅប្រទេស ចំនួន១៨នាក់រួចមកហើយ ក្នុងអំឡុងពេលដែលយើងកំពុងធ្វើការរៀបចំបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួស។ ហេតុអ្វីបានជាគេអាចនាំទារកទាំងអស់នោះចេញទៅក្រៅប្រទេសបាន? គេនៅតែព្យាយាមបន្តនាំយកទារកចេញ ដោយគេមិនអាចរង់ចាំបាន។ យើងកំពុងតែរៀបចំច្បាប់ពាក់ព័ន្ធករណីនេះឲ្យបានលឿន ព្រោះយើងនៅតែចាញ់ប្រៀបគេដោយគេយកច្បាប់ប្រទេសគេមកធ្វើការអនុវត្តនៅក្នុងប្រទេសយើង។ សូមឲ្យគ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធលើកឡើងជាមតិយោបល់ពាក់ព័ន្ធនឹងការរៀបចំបែបបទ និងនីតិវិធីខាងលើទៅតាមជំនាញរៀងៗខ្លួន។

អង្គប្រជុំបានបន្តសម្រេចធ្វើការកែសម្រួលខ្លឹមសារ នៃគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួស ដូចខាងក្រោម៖

អ្នកស្នើសុំកូនដែលជាជនបរទេស ត្រូវដាក់ពាក្យស្នើសុំកូនទៅតុលាការតាមរយៈស្ថានទូតសាមីរបស់អ្នកស្នើសុំដើម្បីទាមទារបិតុភាពដោយមាន ភស្តុតាងកោសល្យវិច្ច័យ DNA និងសុំសិទ្ធិគ្រប់គ្រងកូនដើម្បីអាចនាំកូនចេញទៅក្រៅប្រទេសបាន។

**១. ឯកសារពាក់ព័ន្ធបុរសជនបរទេសដែលអះអាងថាជាឪពុក**

សេចក្តីបញ្ជាក់ស្តីពីភាពត្រឹមត្រូវ នៃឯកសារស្នើសុំទាំងអស់របស់សាមីខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច ឬស្ថានទូត នៃប្រទេសសាមីរបស់អ្នកស្នើសុំមានជាអាទិ៍៖

- ពាក្យស្នើសុំមានបិទរូបថតសាមីខ្លួនរបស់អ្នកស្នើសុំ និងសហព័ទ្ធ(បើមាន)
- លិខិតបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសដែលមានចំណងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា
- របាយការណ៍សង្ខេបអំពីស្ថានភាពគ្រួសារ ដែលមានការទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ច ឬអាជ្ញាធរប្រទេសសាមី បញ្ជាក់ពីមូលហេតុ និងគោលបំណង នៃការពពោះជំនួសកន្លងមក
- សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណ ស្ត្រីពពោះ(ស្ត្រីខ្មែរ)
- សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍ ឬលិខិតលែងលះ ឬលិខិតបញ្ជាក់ភាពនៅលីវ ឬលិខិតមរណៈភាព របស់សហព័ទ្ធ និងភាពចាំបាច់ដែលត្រូវសុំយកកូនទៅចិញ្ចឹមជាកូនរបស់ខ្លួន
- លិខិតបញ្ជាក់ DNA ដែលធានាថាខ្លួនជាម្ចាស់មេជីវិត
- លិខិថ្កោលទោស ចេញដោយអាជ្ញាធរប្រទេសកំណើត និង/ឬ ប្រទេសដែលសាមីខ្លួនអ្នកស្នើសុំរស់នៅអចិន្ត្រៃយ៍បីឆ្នាំចុងក្រោយ
- សេចក្តីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- លិខិតឆ្លងដែន របស់សាមីអ្នកស្នើសុំ

សំណុំលិខិតទាំងអស់ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបន្តនីតិវិធី។

២. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ទទួលពាក្យស្នើសុំដែលបញ្ជូនមកពីស្ថានទូតសាមីរបស់អ្នកស្នើសុំកូន តាមរយៈតុលាការកម្ពុជា ដោយភ្ជាប់ជាមួយ៖

- សេចក្តីសម្រេចពីតុលាការបញ្ជាក់ បិតុភាពបុរសជាសាមីខ្លួនជនជាតិបរទេសស្នើសុំដែលមានពិសោធន៍ DNA និង ផ្ទេរសិទ្ធិអាណាព្យាបាលពីស្ត្រីពពោះលើទារកទៅបុរសជនបរទេស ដើម្បីមានសិទ្ធិនាំយកទារកទៅចិញ្ចឹមនៅប្រទេសខ្លួន។
- លិខិតផ្តល់សញ្ជាតិពីអាជ្ញាធរប្រទេសសាមីអ្នកស្នើសុំ

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើការពិនិត្យ និងផ្តល់យោបល់ ទៅក្រសួងមហាផ្ទៃ ដើម្បីអនុវត្តនីតិវិធីបន្ត។

៣.ក្រសួងមហាផ្ទៃ

ទទួលសំណុំលិខិតដែលបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ភ្ជាប់ដោយ សជណ ដើម្បីពិនិត្យលើលក្ខខណ្ឌសមស្របទាំងឡាយដែលគួរអនុញ្ញាត ឬត្រូវបំពេញបន្ថែមរួចចេញលិខិតមក៖

ក. អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម៖ ចេញលិខិតបញ្ជាក់កំណើតជាថ្មី ក្នុងករណីមានសេចក្តីសម្រេចរបស់តុលាការ។

ខ. ចេញ សជណ អនុញ្ញាតឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ផ្តល់ទិដ្ឋាការចេញឲ្យសាមីខ្លួននាំទារកចេញទៅក្រៅប្រទេសសាមីតាមផ្លូវច្បាប់។

ចុងបញ្ចប់ នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានខិតខំយកចិត្តទុកដាក់លើការកែសម្រួល គោលការណ៍ណែនាំ ស្តីពី ពីបែបបទ និងនីតិវិធីស្នើសុំកូនករណី នៃការពពោះជំនួសដើម្បីយកទារកទៅចិញ្ចឹមនៅក្រៅប្រទេស ។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសែសិបប្រាំនាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ទោ ឌិក_សត្យា

**គោរពជូន**

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧

ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប

ឧត្តមសេនីយ៍ទោ. គង់_ពុទ្ធី